ឧប សៅ សង្ហា

# គំនិត នៃការប្រកាន់ពូជសាសន៍ និង ចិត្តគំនិតខ្មែរ



និមិត្តរូបនៃការប្រកាន់ពូជសាសន៍

**ការសាកល្បងពិចារណា អំពីគំនិតនយោបាយ**

## មាតិការឿង

គំនិត នៃការប្រកាន់ពូជសាសន៍ 1
ចិត្តគំនិតខ្មែរ 15
សិក្ខាបទ នៃព្រះដ៏មានព្រះភាគ 22

និព័ន្ធដោយ ឧប សៅ សង្ហា
ខែ ឧសភា ឆ្នាំ ២០១៨



និមិត្តរូបនៃការ ប្រឆាំងនិងការ ប្រកាន់ពូជសាសន៍

Nelson Mandela

# គំនិត នៃការប្រកាន់ពូជសាសន៍

ជាទ្រឹស្តីនយោបាយ និង គោលគ្រឹះ នៃទ្រឹស្តី នៃប្រវត្តិសាស្ត្រ ការប្រកាន់ពូជសាសន៍ វាក្លាយជាកត្តា នៃប្រវត្តិសាស្ត្រ នៅអឺរ៉ុបនៅពាក់កណ្ដាលសតវត្សទី១៩។ ជាកម្លាំងនយោបាយ វាបង្ហាញជារស្មីត្រចង់ នៅពេលនោះ តាមរយៈ នៃការប្រកាន់ពូជសាសន៍ហ្ស៊ីហ្វ និង បង្កបង្កើត នូវគោលគ្រឹះនៃបញ្ញា របស់ ណាស៊ីនិយម (Nazisme)។

ការពន្យល់ដំបូង លើលោក នៃមនុស្សា តាមពូជសាសន៍ វាមានតាំងពីសតវត្សទី១៨ម្លេះ។ នៅពេលនោះ នរវិទ្យាដែលទើបនឹងលេចឡើង ល្បងនឹងកំណត់ ទីស្ថាន នៃមនុស្សនៅក្នុងធម្មជាតិ ដោយប្រើ គោលវិធីសំអាង លើការពិសោធ គឺថា គេសង្កេតមើលមនុស្ស, គេយកមកប្រៀបធៀបគ្នា, គេប្រមាណ។ គេស្វែងរកផងដែរ នូវការកំណត់អំពីអ្វី ដែលបង្កើត នូវឯកភាព និង សុខដុមរមនា នៅក្នុងសង្គម។ រួចតាមដំណើរហេតុទាំងឡាយនោះ គេមានជំនឿលើ ឯកភាព នៃរូបងកាយ និង វិញ្ញាណ នៃបរិសា[1]

[1] បរិសា : ក្រុម។

មនុស្សផ្សេងៗគ្នា។ ដូច្នេះ គេធ្វើការសន្និដ្ឋានថា គេអាចធ្វើការសង្កេត នូវវត្ថុធាតុទាំងឡាយនោះបាន ហើយនឹងអាចប្រមាណវាបានទៀតផង។

លោក Lamarck (១៧៧៤-១៨២៩) ជាអ្នកបើកផ្លូវ ដោយបានសរសេរសៀវភៅ អំពីទស្សនវិជ្ជា នៃសត្វវិទ្យា (១៨០៩) និងនាំអោយលោក Darwin និង លោក Buffon (១៧០៧-១៧៨៨) ជាអ្នកនិព័ន្ធសៀវភៅអំពី ប្រវត្តិសាស្ត្រធម្មជាតិនៃមនុស្ស (១៧៧៨) យកមកធ្វើជាគោលគំនិត ហើយស្នើរួមគ្នា តាមការពន្យល់ជាសម្ភារៈ ឬ តាមរូបភាព អំពី ភាពខុសគ្នា នៃពូជសាសន៍មនុស្ស ទៅតាមមជ្ឈដ្ឋាន តែលក្ខណវិនិច្ឆ័យ នៅក្នុងសំណើរនោះ វាស្ថិតនៅត្រឹមតែនៅក្នុងគំនិត អត្តវិស័យ (subjectif) នៅឡើយ តែគោលគំនិតនេះ វារាលដាល នៅអឺរ៉ុប និង នាំអោយ មនុស្សមួយចំនួនជឿជាក់ថា ភាពខុសគ្នា នៃរូបកាយ វាបង្ហាញថា ក៏វាមានភាពខុសគ្នា នៃចរិត, ផ្លូវចិត្ត និង វប្បធម៌ផងដែរ។

ចាប់ពីដើមសតវត្សទី១៩, អត្ថបទវិទ្យាសាស្ត្រមួយចំនួន ស្តីពី ប្រវត្តិសាស្ត្រនៃធម្មជាតិ ឬ នរវិទ្យា សុទ្ធតែមានលក្ខណៈជាការប្រកាន់ពូជសាសន៍។ វិទ្យាសាស្ត្រ នៃនរជាតិថ្មីនេះ បានចម្លង ស្ទើរដូចវិទ្យាសាស្ត្ររូបវិទ្យា មាននិន្នាការទៅរកការសន្មត់ថា ចរិតផ្លូវចិត្ត វាមានភ្ជាប់ជាមួយនឹង ចរិត

លក្ខណៈផ្លូវកាយ។ ដ្បិត ជនស្បែកខ្មៅ គឺខ្មៅតពូជ ហើយ ជា ជនខ្ជិលច្រអូស តពូជផងនោះដែរ។

ការប្រកាន់ពូជសាសន៍ នៅសតវត្សទី១៩ វាមានលក្ខណៈ កំណត់ តាមការស្វែងរក ការជាប់ទាក់ទងគ្នា រវាង ចិត្ត និង កាយ។ នៅអឺរ៉ុប នៅពេលនោះ មានគំនិតពីរ រាលដាលយ៉ាងទូលំទូលាយ : គំនិតទី បញ្ជាក់ថា វាមាន ការខុសគ្នាជាចាំបាច់ នៃផ្លូវចិត្ត នៅក្នុងខ្លួនប្រាណមនុស្ស រវាង ពូជសាសន៏ខុសគ្នា។ គំនិតទី២ ចង់បង្ហាញថា ប្រជាជន មួយក្រុម ដែលមានឈាមដូចគ្នា វាមានជាចាំបាច់ដែរ នូវមរតវប្បធម៌ និងបញ្ញាតែមួយ។ ត្រូវដឹងថាការរីកចំរើន នៃគំនិតជាតិនិយម វាអនុគ្រោះ នូវការសាកល្បង កំណត់ នូវសម្ពហភាពជាតិ ទៅតាម លក្ខណវិនិច្ឆ័យគោលដៅ និង ភ្ជាប់ នូវការអោយតម្លៃសំខាន់ ទៅលើភាសា និង ប្រវត្តិសាស្រ្តជាតិ ហើយនឹង ការតស៊ូដ៏យូរអង្វែង ប្រឆាំងនឹង គោលគំនិត នៃបដិវត្តន៏បារាំងសែស ដែលគេទុកជាការចង្រៃ មួយនៅអឺរ៉ុប និង មរត នៃវិចារណនិយម មាននៅសតវត្ស នៃពន្លឺបញ្ញា (សតវត្សទី១៨ - ១៧១៥-៨៩) ដែលគេទុកជា គំនិតប្រឆាំងនឹង ច្បាប់ធម្មជាតិ។ គំនិតជាតិនិយមនោះ វានាំសម្រួលដល់ កំណើត នៃការប្រកាន់ពូជសាសន៍ ដែលវា ក្លាយទៅជា ទ្រឹស្តី នៃប្រវត្តិសាស្រ្តផង និង កម្លាំង នយោបាយផង។ ក្នុងន័យនេះ, វាមាននៅក្នុង

ស្នាដៃ របស់លោក Herder ដែលជាស្នាដៃមួយ គួរអោយចាប់អារម្មណ៍ដែរ នៅលើចំណុច នៃគំនិត វិចារណនិយម[2] (rationalisme) និង មនុស្សជាតិ ដែលជាទស្សនៈ បដិសេធនូវគោលការណ៍ នៃការបែងចែកពូជសាសន៍, ក៏ប៉ុន្តែ វាក៏បញ្ចេញឥទ្ធិពល ជាកត្តាកំណត់ ទៅលើគំនិតជាតិនិយមនៅអឺរ៉ុប និង វិធីជាប្រយោល ទៅលើ ការប្រកាន់ពូជសាសន៍ តាមគំនិតអត្តវិស័យមួយ មានឈ្មោះថា Volkgeit : ជីវិត និង វប្បធម៌ នៃប្រជាពលរដ្ឋ រួមគ្នាជុំវិញ រុក្ខរស់ និង អត្តរស់ដើម និងចីរភាព ដែលជាមូលដ្ឋាននៃកម្លាំង របស់ផងខ្លួន[3]។ គំនិត Volkgeit នេះ ត្រូវបានលោក Herder បង្ហាញ តាម ទេវកថាវិទ្យា, ចម្រៀងប្រពៃណី, លោកកថា ឬ រឿងព្រេង។ ជាធម្មតា របស់ទាំងនេះ វាមានតាំងពីដើមកំណើត នៃមនុស្ស និង ត្រូវបានគេថែរក្សាបានល្អ ដែលលោក Herder យកមកកែឆ្នៃបានជាគំនិតថ្មី សំរាប់សំអាង នូវទ្រឹស្តី នៃការប្រកាន់ពូជសាសន៍។ ទស្សនៈអង្គិន

[2] វិចារណនិយម : គោលលទ្ធិ បញ្ជាក់ថា អត្តភាពទាំងឡាយនៅលើលោក ត្រូវតែមានការពន្យល់ ដែលមិនអាចនៅក្រៅ នៃហេតុផលរបស់មនុស្ស។

[3] ពាក្យ « ផង » ប្រើក្នុងន័យ ជាពាក្យ សាមីសម្ពន្ធ។

(concept organique) នៃប្រជាជាតិ នេះ វាធ្លាប់មានឥទ្ធិពលខ្លាំង ទៅលើ ការរីកចំរើន នៃវិសេសនិយម (particularisme) នៅអឺរ៉ុប និង ផ្តល់ នូវមូលដ្ឋាន ដែលក្រុមជាតិនិយមកុលសម្ព័ន្ធ គេយកមកធ្វើជាគោលការណ៍ តួយ៉ាង ជាតិនិយម នៃដែនដី និង មនុស្សស្លាប់, ជាតិនិយម នៃ « ឈាម និង ដី »។ ប្រព័ន្ធកម្ម នៃគំនិតប្រកាន់ពូជសាសន៍ នៅសតវត្សទី១៩ ក៏ជាគំនិត របស់លោក Arthur de Gobineau ផងដែរ។ ការសាកល្បងពិចារណា របស់គាត់ អំពី សមភាព នៃពូជសាសន៍មនុស្ស (១៨៥៣-៥៥) ជាស្នាដៃសំយោគ, អន្តរវិជ្ជា ហើយ លាយនៅក្នុងប្រវត្តិសាស្ត្រវិទ្យា, នរវិទ្យា, ភាសាវិទ្យា។ ចំពោះលោក Gobineau គោលការណ៍ នៃពូជសាសន៍ វាអាចយកបំភ្លឺបាន នូវបច្ចុប្បន្នកាល, អតីតកាល និង អនាគតកាល។ វាកំណត់ នៃវាសនា របស់អរិយធម៌ទាំងឡាយ។ តែ ការប្រឡូកបុប្ផា នៃពូជសាសន៍ វាជាមូលហេតុ នៃអត្តង្គត នៃអរិយធម៌ ព្រោះវាគ្មាន ពូជសាសន៍ណាមួយ អាចថែរក្សារហូតបាន នូវភាពបរិសុទ្ធ របស់ខ្លួន ហើយបើវាមាន កូនកាត់ កាន់តែច្រើន វាកាន់តែបាត់ ធម្មជាតិដើម របស់វាកាន់តែច្រើនដែរ។ តាមលោក Gobineau វាមាន បីពូជសាសន៍សំខាន់ : ពូជសាសន៍ លឿង, ខ្មៅ និង ស។ ពូជសាសន៍លឿង ជាអ្នកសម្ភារៈនិយម ហើយខ្វះ ប្រឌិតញ្ញាណ, រីឯ

ភាសាវិញ វាមិនអាចថ្លែងបញ្ជាក់បាន នូគំនិតមនោសារ ; ពូជសាសន៍ខ្មៅ ខ្វះ បញ្ញា ; នៅក្នុងចំណោមពូជសាសន៍ស មានពូជសាសន៍អរ្យ៉ែន (Aryen) ជាវរៈជន មកពីប្រទេស ឥណ្ឌា បានបង្កើត នូវវប្បធម៌ នៃជនជាតិអាឡឺម៉ង់ នៅ សម័យយុគ កណ្តាល (Teutons) ដែលវាមាន គុណធម៌ នៃ អរិយភាព (noblesse), សេចក្តីស្នេហា នៃសេរីភាព និង ជំនឿ ទៅលើចេតភាព (spiritualité)។ តែ លោក Gobineau គាត់មិនមែនជាជន ប្រឆាំងនឹង ពួកជនជាតិ ហ្សុិហ្វ ហើយគាត់ ជាអ្នកប្រឆាំងនឹង ទាសភាព, ប៉ុន្តែ លោក ពន្យល់ អំពីប្រវត្តិសាស្ត្រ នៃសាកលលោក តាមទ្រឹស្តី ពូជសាសន៍ និង អះអាង នូវវិសិដ្ឋភាព នៃវត្ថុធាតុ នៃពួក ជនអរ្យ៉ែន។ និក្ខេបបទ របស់លោក ត្រូវបានចលនា ផ្ទាំង-នៃភាសាអាឡឺម៉ង់ (pan-germanisme) យកធ្វើជាគោល លទ្ធិ ដើម្បី បញ្ជាក់អំពី គោលគ្រឹះ នៃការប្រកាន់ពូជសាសន៍, ជាតិនិយម និង ជាតិ-សង្គមនិយម។

ប្រទេសអង់គ្លេស ក៏មានដែរ អ្នកនិព័ន្ធ ប្រកាន់ពូជសាសន៍ ដូចយ៉ាង : លោក Robert Knox (១៧៩៨-១៨៦២)។ នៅ ក្នុងសៀវភៅ របស់លោក (Races of men) គាត់បាន អះអាង នូវវិសិដ្ឋភាព របស់ពូជសាសន៍ នៃអរ្យ៉ែន ពីរក្រុម គឺ ពួក Saxons និង Slaves, និង ហីនភាព នៃជនជាតិហ្សុិហ្វ។ ក៏ដូចលោក James Hunt (១៨៣៣-៦៩) ជាស្ថាបនិក

និង ប្រធាន សមាគម នៃនរវិទ្យា នៅទីក្រុងឡុងដ៍ ហើយជាអ្នកកោតសរសើរលោក Knox, លោក បានរួមចំណែកតាមផ្លូវគំនិត ជួយតម្កើងគំនិត ប្រកាន់ពូជសាសន៍ តាមការសរសេរ រិះគន់យ៉ាងខ្លាំង ដើម្បីកំចាត់ចោល នូវខ្លឹមសារ នៃវិទ្យាសាស្ត្រ ដែលលោកទុកជា ការធ្វើវិនិច្ឆ័យទុកមុខ (បុរេនិច្ឆ័យ) ដ៏អកុសល[4] ដូចយ៉ាង សិទ្ធិមនុស្ស និងជំនឿលើ សមភាព រវាងមនុស្សលោក។ អ្នកនិពន្ធទាំងពីរនេះ គិតដូចគ្នាថា គុណភាពនៃសង្គម ទាំងសភាព សីលធម៌, បញ្ញា និង រូបកាយ របស់បុគ្គល គឺវាមានពីកំណើតមក (សជាតិកភាព) ហើយ មិនអាចផ្លាស់ប្តូរវាបានឡើយ។

ការពន្យល់ នៃប្រវត្តិសាស្ត្រ ដែលសង្កត់ទៅលើ កត្តានៃជាតិពិន្ទុ ក្នុងការលូតលាស់ នៃអរិយធម៌ទាំងឡាយ វាមានឥទ្ធិពលទៅលើអ្នកប្រាជ្ញមួយចំនួន។ អ្នកប្រាជ្ញ ដែលលេចមុខចេញជាងគេនៅសតវត្សទី១៩គឺ លោក Hippolyte Taine (១៨២៨-៩៣) ជាអ្នកក្តាប់ គ្មាននរណាប្រកែកបាន នូវជីវិតភាពនៃបញ្ញា នៅប្រទេសបារាំង នៅក្នុងសម័យរបស់

[4] វិទ្យាសាស្ត្រ នៃបុរេនិច្ឆ័យដ៏អកុសល : Science de préjugés malheureux។

គាត់។ លោក បានអះអាង នៅក្នុងសៀវភៅ របស់លោក (l'histoire de la littérature anglaise-1863) ថា អរិយធម៌ វាតែងតែ ផលិតជានិច្ច នូវវត្ថុធាតុ បីយ៉ាង : ពូជសាសន៍, មជ្ឈដ្ឋាន និង ខណៈ។ មនុស្សលោក មានទំនាក់ទំនងគ្នា តាម « សហគមន៍ នៃលោហិត និង វិញ្ញាណ »។ គេតែងទុក លោក Taine ជាអ្នកបតិដ្ឋាននិយម (positiviste) និង សេរីនិយម ដូចគ្នានឹងលោក Ernest Renan ដែលជាអ្នកប្រាជ្ញបារាំងសែស ល្បីល្បាញខ្លាំងមួយដែរ នៅសម័យនោះ ហើយ គំនិត របស់លោក វាមានឥទ្ធិពលច្រើន ទៅលើលោក Gobineau។

ប៉ុន្តែ គំនិតប្រកាន់ពូជសាសន៍ វាអាចក្លាយទៅជា ទ្រឹស្តីនយោបាយមាំមួនបាន តាមការបញ្ជូលទ្រឹស្តី ដាវិននិយម នៃសង្គម[5] (Darwinisme social)។ ទ្រឹស្តី របស់លោក ដាវិន ស្តីពី ការរើសសម្រាំង ជាធម្មជាតិ, ការប្រយុទ្ធដើម្បីមាន អត្តភាព, ការរស់រានមានជីវិត ដើម្បីសម្របខ្លួន វាសុទ្ធជា

---

5 ដាវិននិយមនៃសង្គម ជាគំនិតប៉ុនប៉ង បញ្ចេញអោយឃើញ នៃសទិសភាព នៅក្នុងសណ្តាប់ធ្នាប់សង្គមនឹង ច្បាប់លោកដាវិន ស្តីពីការរើសសម្រាំងជាធម្មជាតិ។

ទស្សនៈ ដែលពួកអ្នកទ្រឹស្តីប្រកាន់ពូជសាសន៍ ពេញចិត្ត ទាំងអស់។ បច្ច័យនិយម[6] ឬ ការប្តេជ្ញាចិត្តនិយម នៃជីវសាស្ត្រ (déterminisme biologique) យកវាមកអនុវត្ត នៅក្នុង មនុស្សសាស្ត្រ វាក្លាយជាបទដ្ឋាន សំរាប់ពួកទាំងនោះ សំរាប់បង្ហាញ នូវភស្តុតាង នៃវិសមភាព របស់មនុស្ស មានពីកំណើត ឬ សំរាប់យកមកបញ្ចូល ទៅក្នុងទ្រឹស្តីមួយ ដើម្បី ស្តារ នូវលំដាប់ធម្មជាតិ ដែលគេជឿថា ត្រូវបាន លទ្ធិសេរីនិយម, លទ្ធិប្រជាធិបតេយ្យ, ការបដិវត្តន៍បារាំងសែស ឬ លទ្ធិម៉ាក្សនិយម បានបំផ្លាញខ្ទេចខ្ទី។

សំយោគ នៃការប្រកាន់ពូជសាសន៍ និង ទ្រឹស្តី ដាវិននិយម នេះ វារាលដាលនៅអឺរ៉ុប នៅចុងសតវត្សទី១៩។ សំយោគនេះ ត្រូវបាន លោក Georges Vacher de Lapouge នៅប្រទេសបារាំង និង លោក Otto Amon នៅប្រទេសអាឡឺម៉ង់ យកមកបង្ហាញ តាមការសរសេរ ជាបែបបទចរិតលក្ខណៈ គឺថា មិនគ្រាន់តែ អះអាង នូវវិសិដ្ឋភាពដាច់

6 បច្ច័យនិយម : ទ្រឹស្តី នៃទស្សនវិជ្ជា ស្តីពី បាតុភូតធម្មជាតិទាំងឡាយ និង សកម្មភាព នៃមនុស្ស ត្រូវ បានភ្ជាប់គ្នា តាមអំពើពីដើម របស់ខ្លួន ឬ គោលការណ៍ នៃមូលហេតុ។

ខាត - រូបកាយ, សីលធម៌ និង សង្គម - នៃពូជអរ្យ៉ែន (វិសិដ្ឋភាព ដោយផ្អែកលើ ទំហំខួរក្បាល និង លក្ខណវិនិច្ឆ័យ នៃសង្គម, នរវិទ្យា និង សេដ្ឋកិច្ច) តែ រហូតស្មើ នូវទស្សនៈថ្មីមួយ នៃធម្មជាតិមនុស្ស និង គំនិតថ្មី ស្ដីពី ការប្រាស័យទាក់ទង របស់មនុស្ស។ នៅក្នុងសំណើរនោះ គាត់ នាំគ្នាយល់ឃើញថា ការបែកចែកនៃមនុស្សនៅក្នុងសង្គមវាស្ថិតនៅក្រោមបង្គាប់ យ៉ាងតឹងរឹក នៃ គំនិតបច្ច័យនិយម និង គ្មានអ្វីអាចទម្លាក់ចោលបាន នូវបុព្វវាសនា នៃពូជសាសន៍ បាននោះឡើយ។ ចំពោះគាត់ គឺវត្ថុធាតុ អរ្យ៉ែនដែលតែងតែលីទម្ងន់ ប្រវត្តិសាស្ត្រ ជានិច្ច និង ជាអ្នកស្ថាបនា នៃអរិយធម៌, បង្កើត សិល្បៈ និង វិទ្យាសាស្ត្រ, រកឃើញប្រទេសថ្មីៗជាច្រើន នៅក្នុងពិភពលោក, នាំបង្កើតសកម្មភាពសេដ្ឋកិច្ច។

ក្រោយមក ពួកអ្នកតំណាង នៃសាលាគំនិតនេះ គេអះអាងថាមាន សហសម្ព័ន្ធដាច់ខាត មិនត្រឹមតែ រវាងខ្លួនប្រាណ ជាមួយនឹង សកម្មភាពបញ្ញា តែវាមានផងដែររវាង ទំហំ នៃលលាក្បាល និង ភ័ព្វសំណាងនឹងអាចឡើងឋានៈបាន នៅក្នុងថ្នាក់សង្គម របស់ក្រុមមនុស្សមួយ ដែលគេអាចប្រមាណបាន តាមការវាស់វែង នៃទំហំលលាក្បាល របស់ជនទាំងនោះ និង អណ្ដាប់ នៃការវិវត្តន៍ចេតសិក (spirituel) របស់ក្រុមមនុស្សនោះ។ ជាធម្មជាតិ គេអាច

ទុក ទ្រឹស្ដី ដាវិននិយមនៃសង្គម ជាសម្ពន្ធមិត្តនិង ទ្រឹស្ដី នៃការប្រកាន់ពូជសាសន៍ ហើយ វាមានអនុភាពភ្លាមៗ លើគំនិតប្រមាថ ដល់នរជាតិ និង ការប្រៀបធៀប នៃ អត្តភាព និង រូបកាយ នៃមនុស្ស នៅក្នុងសង្គម។

តាមការយល់ឃើញ នៃពួកអ្នកប្រកាន់ពូជសាសន៍ សង្គម ជាអង្គការមួយ គ្រប់គ្រង ដោយច្បាប់តែមួយ ដូចគ្នានឹង សរីរាង្គទាំងឡាយដែរ។ ប្រភេទទាំងឡាយ នៃមនុស្ស និង សត្វ វាស្ថិតនៅក្រោមច្បាប់តែមួយ ហើយ ជីវិត នៃមនុស្ស វាជាការប្រយុទ្ធ មិនចេះចប់ ដើម្បីបង្ហាញ នូវអត្តភាព របស់ខ្លួន។ លើលោកនេះ គឺជាទីកន្លែង សំរាប់តែ អ្នកខ្លាំង ជា អ្នកថ្លៃថ្លា ហើយ នៅក្នុងទស្សនៈនេះ លោក Vacher ស្នើ ថា ឱ្យយក សីលធម៌ ផ្អែកលើគោលគំនិត នៃ « ការរើស សម្រាំង » នៃប្រភេទសត្វលោក មកជំនួស សីលធម៌បុរាណ នៃសាសនាគ្រិស្ត ទើបវាមានប្រត្យក្សភាព។

នៅចុង សតវត្សទី១៩, គំនិត នៃវិសមភាព នៃជាតិពិន្ទុ នៃប្រជាជនផ្សេងៗគ្នា វាក្លាយជាគំនិតលេចធ្លោឡើងនៅ ពេលនោះ។ ស្នាដៃ របស់អ្នកនិព័ន្ធជាច្រើន សំដែង នូវ គំនិតប្រកាន់ពូជសាសន៍ ហើយជារឿយៗ គឺតម្រង់ទៅពួក ជនជាតិហ្សីហ្វ។ ស្នាដៃទាំងនោះ ផ្អែកលើ គំនិតសំយោគ រវាង ទ្រឹស្ដីប្រកាន់ពូជសាសន៍ និង ដាវិននិយមនៃសង្គម

នៅអឺរ៉ុប។ ស្នាដៃខ្លះ មានជោគជ័យណាស់ - តួយ៉ាង នៅប្រទេសបារាំង សៀវភៅមួយ មានចំណងជើងថា « La France Juive – 1886 » សរសេរដោយលោក Drumont។ ស្នាដៃ របស់លោក Gustave le Bon សរសេរអំពី ចិត្តវិទ្យាសង្គម ក្នុងនោះលោក បានអោយសារៈសំខាន់ណាស់ទៅលើ កត្តាពូជសាសន៍។ សៀវភៅដ៏ល្បីល្បាញនេះ ត្រូវបានគេយកទៅបកប្រែ ១៦ ភាសា។ តាមលោក Drumont ក៏ដូចលោក Lagarde (អ្នកនិព័ន្ធសៀវភៅមួយ មានចំណងជើងថា Deutsche Schiften – 1876) មានគំនិតថា ជនជាតិហ្សុីហ្វ ជាសត្រូវ និង ជាអ្នកឈ្លានពានគ្មានទីបំផុត មកលើពូជសាសន៍អរ្យ៉ែន។ គំនិតនេះ ក៏បានលោក Wagner ធ្លាប់បានសរសេរដែរនៅឆ្នាំ ១៨៥០ នៅក្នុងសៀវភៅ របស់គាត់ មានចំណងជើងថា Judentum in der Musik។

គំនិតទាំងនោះ វាជាគំនិតមជ្ឈឹម នៅក្នុងចិន្តា របស់លោក Houston និង Stewart Chamberlain ជាអ្នកទ្រឹស្តីពិស្សុត នៃការប្រកាន់ពូជសាសន៍ ដោយបានសរសេរសៀវភៅ មានចំណងជើងថា « les fondements du XIXè siècle - 1899 » និង Geshlecht und Charakter ជាសៀវភៅ សរសេររួមជាមួយលោក Otto Weininger នៅឆ្នាំ ១៩០៣។ សៀវភៅទាំងនោះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើលោក Hitler។ តាមលោក Chamberlain ជនជាតិហ្សុីហ្វ ជា

តំណាង នៃអកុសលដាច់ខាត រីឯ ជនជាតិអាឡឺម៉ង់វិញ ជាប្រជាជន ដែល ព្រះបានជ្រើសយក (peuple élu)។ ដូច្នេះ វាសនា នៃអរិយធម៌ វាអាស្រ័យទៅលើ ការប្រយុទ្ធ រវាង ពួកហ្សិហ្វ និង ពួកអរ្យ៉ែន។ ជ័យជំនះ នៃពួកហ្សិហ្វ គឺទុកស្មើ នឹងអន្តរាយ នៃអរិយធម៌, រីឯជោគជ័យ នៃពួកអរ្យ៉ែនវិញ គឺជាដើមទី នៃការបដិវត្តន៍ ចេតសិក។ ជាជោគជ័យមួយ ដាក់ជាសញ្ញា នូវអវសាន នៃភាពអន់ថយ នៃអរិយធម៌ និង ជាកំណើត នៃយុគថ្មី។

មនោគមវិជ្ជា នៃការប្រកាន់ពូជសាសន៍, អាងហេតុលើ មូលដ្ឋាន នៃវិទ្យាសាស្ត្រមិនពិត (speudo-science), ជា ពិសេស លើគំនិតថា ពួកជនជាតិហ្សិហ្វ ជាពូជសាសន៍ មានភាពទាប ដែលគេអាចពន្យល់បាន, វាមានតួនាទី សំខាន់ណាស់ នៅក្នុងអភិក្រម ដែលនាំអោយមាន ការ បំផ្លាញ ដល់គ្រប់វប្បធម៌ នៃនយោបាយ ផ្អែកលើមូលដ្ឋាន វិចារណនិយម, បុគ្គលនិយម និង សិទ្ធិមនុស្ស។ មនោគម វិជ្ជានេះ វាមិនគ្រាន់តែមានឥទ្ធិពលខ្លាំង នៅប្រទេសអាឡឺ ម៉ង់ តែវាក៏ជ្រាបចូលជាជម្រៅ ទៅក្នុងប្រទេសដទៃទៀត បីដូច ប្រទេសអ៊ីតាលី ដែលបានបង្កើតច្បាប់ប្រកាន់ពូជ សាសន៍នៅឆ្នាំ ១៩៣៨ និង ប្រទេសបារាំង ដែលរបប Vichy នៅឆ្នាំ ១៩៤០ បានបង្កើតច្បាប់ប្រឆាំងនឹង ពួក

ជនជាតិហ្វ្រិហ្វ ហើយយកវាមកអនុវត្ត។ ច្បាប់ទាំងនោះ វាស្រដៀងគ្នានឹង ច្បាប់ពួកណាស៊ី នៅទីក្រុង Nuremberg។



ផ្ទះទឹក នៃសហគម យួន នៅបឹង ទន្លេសាប

# ចិត្តគំនិតខ្មែរ

តើ ជនខ្មែរ ជាអ្នកប្រកាន់ពូជសាសន៍ ឬទេ ? នៅក្នុងប្រវត្តិសាស្ត្រ នៃប្រជាជាតិខ្មែរ វាគ្មានឃើញស្នាម នៃជម្លោះរវាងជាតិសាសន៍នោះឡើយ ; ម្យ៉ាងមួយទៀត សង្គមខ្មែរមានជាតិសាសន៍សភាគ នៅក្នុងអំបូរ ខ្មែរ-មន។ រដ្ឋខ្មែរ-កកើតឡើង ជារដ្ឋមានការរៀបចំ តាមគំរូ ហិណ្ឌូ មានអាគតដ្ឋានពីឥណ្ឌា ប៉ុន្តែឥទ្ធិពល នៃព្រហ្មញ្ញសាសនា ពាក់ព័ន្ធនឹងវណ្ណៈសង្គម វាមានអានុភាពកំរិតទាប នៅក្នុងមជ្ឈដ្ឋាន នៃប្រជារាស្ត្រខ្មែរ ព្រោះជីវភាពរស់នៅរាល់ថ្ងៃ នៃរាស្ត្រខ្មែរ វាមានលក្ខណៈ ជាគ្រួសារ នៅក្នុងគំនិត ជាញាតិសន្តាន។ ភូមិខ្មែរ ជាភូមិគ្រួសារ តាមគំនិត ដូច្នេះ សាមគ្គីភាព និង សមភាព វាជាមូលដ្ឋាន នៃការប្រាស័យទាក់ទងរវាងជនខ្មែរទាំងឡាយ ដែលជារបងការពារជាធម្មជាតិនៃការហូរចូលមកក្នុងសង្គមខ្មែរ នូវទ្រឹស្តី នៃការបែងចែកសង្គមមនុស្ស ជាវណ្ណៈ។ គោលគំនិតនេះ វាផ្ទុយស្រឡះពី ការយល់ឃើញមួយចំនួន នៃគោលគំនិត នៃការប្រកាន់ពូជសាសន៍ តួយ៉ាងដូចគំនិត របស់លោក Vacher : ទុកទីកន្លែងរស់នៅ នៃមនុស្ស សំរាប់តែ អ្នកខ្លាំង ជា អ្នកថ្លៃថ្លា ដែលជាគំនិត មានអាគតដ្ឋានពី ដាវិននិយមនៃសង្គម ដែលមានមូលហេតុ ចេញពី ច្បាប់ នៃការរើសសម្រាំង ជាធម្មជាតិ ដែលសត្វលោក ត្រូវតែទទួល

រង។ ផ្ទុយទៅវិញ នៅក្នុងចិត្តគំនិតខ្មែរ តែងតែទុកអ្នកថ្លៃថ្លា ជាអ្នកបានប្រកាក់ប្រកបដោយផលល្អប្រសើរ ពីការធ្វើប្រធានានុយោគ[7] នូវអំពើល្អត្រួតគ្នា ក្នុងសុច្ចន្ទៈ របស់គេ នៅក្នុងអតីតនានាជាតិជាច្រើនកំណើត។ ដូច្នេះ ចិត្តគំនិតខ្មែរ ទុក វិសិដ្ឋភាព នៃពុទ្ធធម៌ លើច្បាប់ធម្មជាតិ : មនុស្សថ្លៃថ្លា ជាមនុស្សមានធម៌។ មានធម៌ គឺកើតឡើងពីការស្វែងរកធម៌ ដោយធ្វើការព្យាយាមសិក្សាធម៌។ ជនខ្មែរទាំងឡាយ ជាពុទ្ធបរិស័ទ ដែលប្រោនចោល នូវគំនិត នៃការបែងចែកនរជាតិ ជាពូជសាសន៍ខុសគ្នា ព្រោះនៅក្នុងពុទ្ធប្រញ្ញប្តិ តែងតែទុកមនុស្សនៅក្នុងលោក នៅក្រោមធម៌ស្មើគ្នា លើកលែងតែបុគ្គលណា ដែល ប្រព្រឹត្តអំពើអកុសល ជាអមនុស្ស ឬ តិរច្ឆាន។ ដូច្នេះ មនុស្ស ជាភាវៈមនុស្សតែមួយ, ការបែងចែកមនុស្ស ជា សុជន ឬ អសុជន គឺស្ថិតនៅលើអំពើ ដែលបុគ្គលបានប្រព្រឹត្ត។ ទស្សនៈនេះ វាប្រហែលនឹងគំនិតលោក Jean-Jacques Rousseau : មនុស្សកើតឡើង ជាជនល្អប្រសើរពីកំណើត តែសង្គម ជាអ្នកនាំខូច។ ដូច្នេះ សង្គមត្រូវមានច្បាប់ សំរាប់ធានា

---

[7] ប្រធានានុយោគ : ការបំពេញព្យាយាមដ៏មុឹងម៉ាត់។

រ៉ាប់រង នូវអំពើល្អនៅក្នុងសង្គម ក៏ដូចគ្នានឹង ពុទ្ធធម៌ ជាផ្លូវ សំរាប់នាំមនុស្សអោយប្រព្រឹត្ត នូវអំពើល្អ, ដូច្នេះ វាគ្មានការបែងចែក មនុស្ស ពីកំណើត ជាភាវៈខុសគ្នានោះឡើយ តែថា បុគ្គលសង្គម វាអាចខុសគ្នា។ ជាធម្មជាតិ, ជនខ្មែរ ជាភាវៈមនុស្ស និង បុគ្គលសង្គម គ្មានមានគោលគំនិត នូវការបែងចែកពូជសាសន៍ នោះឡើយ ព្រោះសង្គមខ្មែរ ជាសង្គមសភាគ និង ទុកពុទ្ធធម៌ ជាគ្រឹះមូលដ្ឋាន នៃការរស់នៅក្នុងសង្គម។ តែថា វាមិនអាចទប់បានចំពោះបុគ្គលខ្មែរខ្លះ និង ក្រុមជនខ្មែរខ្លះ ជាមនុស្ស និង ក្រុម ប្រកាន់ពូជសាសន៍នោះទេ ព្រោះសង្គមខ្មែរ បានទទួលឥទ្ធិពល គ្រប់គំនិតនយោបាយ មាននៅលើពិភពលោក ដែលនាំអោយជនខ្មែរខ្លះ មានប្រតិកម្ម ជាអ្នកប្រកាត់ពូជសាសន៍ ដើម្បី ការពារជាតិសាសន៍ខ្មែរ និង អ្នកខ្លះទៀត ដើម្បី អះអាង នូវវិសិដ្ឋភាព នៃជាតិសាសន៍របស់ខ្លួន។ តែការយកគំនិត នៃប្រកាន់ពូជសាសន៍ មកធ្វើជាអាវុធ សំរាប់ការពារជាតិសាសន៍ វាជាគំនិត នៃការប្រកាន់ពូជសាសន៍នោះឯង។ ដូច្នេះ គំនិតនេះ វាមិនអាចទុកបាន ជាកាលៈទេសៈបន្ធូរបន្ថយនោះឡើយ។ ម្យ៉ាងមួយទៀត មហានគរខ្មែរ មិនមែនកសាងឡើយនៅក្នុងគំនិត នៃវិសិដ្ឋភាព នៃជាតិសាសន៍ខ្មែរនោះទេ ដែលជនខ្មែរមួយចំនួន តែងយល់ច្រឡំ, មហានគរខ្មែរ គឺជា និមិត្តរូប

នៃសាមគ្គីភាពខ្មែរ និង របបដឹកនាំមានពន្លឺបញ្ញា។ តែថា គំនិតការពារជាតិ វាពុំមែនជាគំនិត នៃការប្រកាន់ពូជសាសន៍នោះដែរ បើជាតិខ្មែរ ទទួល នូវការឈ្លានពានជាក់ស្តែង ពីសំណាក់ប្រទេស ឬ ជាតិសាសន៍ដទៃ។ ទង្វើការពារនៅក្នុងលក្ខណៈបែបនេះ វាបញ្ជាក់បន្ថែម លើអំពើ ដែលកំណត់ នូវគុណសម្បត្តិ របស់បុគ្គល មាននៅក្នុងពុទ្ធធម៌ : បុញ្ញកម្ម ( action méritoire) ជាកុសល, ដូច្នេះ ការការពារនៃប្រជាជាតិ ជាកុសល ព្រោះវាមានសច្ចនៈ (បំណងត្រឹមត្រូវ) ដែលជនខ្មែរទាំងឡាយ មិនត្រូវមានការសង្ស័យនោះឡើយ។ សព្វថ្ងៃ ពលរដ្ឋខ្មែរទាំងឡាយ នាំគ្នាត្រិះរិះថា សន្តិភាព ដែលរបបដឹកនាំបច្ចុប្បន្ន គេផ្តល់អោយ វាគ្រប់ល្មមសំរាប់រស់ ព្រោះឃើញមាន ការចំរើនមួយចំនួនអាចទទួលបាន តែគំនិតនេះ វាគ្រាន់តែជាការស្រមើស្រមៃ ឬ ភាន់ប្រមា[8] ដូចគេបោះដែកគោល ផ្ជាប់នឹងសេចក្តីអស់សង្ឃឹម ដែលវាមានអាគតដ្ឋាន ពីការអត់ធ្មត់ទ្រាំទ្រ ដើម្បីរស់រស់តែប៉ុណ្ណោះ ព្រោះយល់ឃើញថា ប្រជាពលរដ្ឋខ្មែរ ឬ ខ្លួនឯងជាខ្មែរ លែងមានលទ្ធភាព ជាកម្លាំងជាតិ ដើម្បី ការពារ

---

[8] ភាន់ប្រមា : ភាន់សេចក្តីដឹង ឬ ប្រាជ្ញា។

ជាតិទៀតហើយ។ ការបោះបង់សិទ្ធិ ជាពលរដ្ឋ និង សេចក្តីសង្ឃឹម នេះឯង ជាលាភផលសោវណ្ណ របស់យួនកុម្មុយនិស្តដើម្បីបំរើមហិច្ឆិតាម៉ឺនឆ្នាំរបស់គេ គឺ យកស្រុកខ្មែរ ទៅបញ្ចូលក្នុងមហាវៀតណាម។ តែថា ប្រជាពលរដ្ឋខ្មែរ និង យួនមិនមែនជា សត្រូវជាតិសាសន៍នឹងគ្នានោះឡើយ។ ជម្លោះជាប្រវត្តិសាស្ត្រ រវាង ស្រុកខ្មែរ និង យួន ជាប្រាឃាត[9] នយោបាយដែនដី ដែលពួកយួនកុម្មុនិស្ត គេបន្តបង្កើតជានិច្ច សំរាប់ទន្ទ្រានស្រុកខ្មែរ ដើម្បី ពង្រីកដែនដីយួន ជាទឹកដីសំរាប់ជីវិត (espace vitale) របស់ប្រជាជនយួន ដែលកាន់តែមានចំនួនច្រើនឡើងៗ, ដូច្នេះគេត្រូវការទឹកដីសំរាប់រស់នៅ។ អង្គហេតុនេះឯង ជាការពិត ដែលប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ កំពុងបន្ត អោបដៃប្រឈមមុខ ហេវកម្លាំងដោយអកម្ម ទទួលយកមកធ្វើជា កម្មវាសនាគេចមិនផុត។ គំនិត ជាអ្នកជតានិយម (fataliste) នេះជា ហឹនមានៈ នាំអោយព្រួញខ្លួន និង លាក់នៅក្នុងអារម្មណ៍នោះឯង។ ជាធម្មជាតិ ជនខ្មែរទាំងឡាយ ពិតជាគ្មានគំនិត

[9] ប្រាឃាត : ច្បាំងគ្នាវរវឹក, កើតមានវិវាទ។

ប្រកាន់ពូជសាសន៍ តែក៏នាំគ្នា បោះបង់ចោល នូវជោគនាការ[10] នៃជាតិសាសន៍ខ្លួននោះដែរ ដែលវានាំអោយ សង្គមខ្មែរ ប្រែក្លាយពី សង្គមនៃសមូហភាព[11] ទៅជាសង្គម នៃឯកត្តភាព[12] អរូបិយ។ ការប្រែផ្លាស់រូបនេះឯងជា ជីវិតន្តរាយ នៃប្រជាជាតិខ្មែរ ព្រោះជនខ្មែរម្នាក់ៗ រមែងតែងតែបាត់អស់ នូវសញ្ញាសំគាល់ នៃជាតិសាសន៍របស់ខ្លួន និង ប្រយូរញាតិពិត ដូចជនខ្មែរទាំងឡាយ នៅសម័យអត្ថុង្គត នៃបោរាណានុបោរាណ[13] បាត់ នូវប្រមា[14] នៃប្រវត្តិសាស្ត្រជាតិខ្មែរ របស់ខ្លួននោះដែរ។ ម៉្យាងទៀត វានាំអោយសង្គម នៃជាតិសាសន៍ខ្មែរ មានបំណែកជាក្រុមបដិបក្ខ ដែលនាំអោយជនខ្មែរម្នាក់ៗ លែងទុកខ្លួនជាសមាជិកសម្ព័ន្ធ (membre d’appartenance) នៃសង្គម

---

10 ជោគនាការ : អាការនៃសេចក្ដីរុងរឿង, អ្នកដែលមានសេចក្ដីអាការរុងរឿង។
11 សង្គមនៃសមូហភាព : société collectiviste។
12 សង្គមនៃឯកត្តភាព : société d’individualité។
13 បោរាណានុបោរាណ : បុរាណមុនៗនិងបុរាណជាលំដាប់បន្ទាប់ៗមក។
14 ប្រមា : សេចក្ដីដឹងច្បាស់។

ជាតិសាសន៍ ជាម្ចាស់ស្រុក តែបែរជានាំគ្នាជឿ តាមការឃោសនា របស់ពួកកុម្មុយនិស្តយួន ថា ស្រុកខ្មែរ ជាស្រុកមាន ពហុជាតិសាសន៍ពីកំណើតមក ដែលជាសហគមន៍ផ្សេងៗគ្នា មាន យួន ចិន ចាម និង អ្នកស្រុកភ្នំទាំងឡាយ រួមរស់នៅស្រុកខ្មែរ តាំងពីយូរអង្វែងមកហើយ។ តែ ប្រវត្តិសាស្ត្រទេ បានហែកសហគមន៍ផ្សេងៗគ្នានោះ អោយក្លាយជាសត្រូវនឹងគ្នា[15] ដែលសព្វថ្ងៃ, នៅក្នុងប្រលឹងស្មារតី នៃថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩, ត្រូវបាន គណបក្សយួនកុម្មុយនិស្ត ជាអ្នកជួយ បង្រួបបង្រួមឡើងវិញ អោយអាចរស់រួមគ្នាបាន នៅក្នុង សង្គម នៃសញ្ជាតិកម្ពុជាតែមួយ។ សព្វថ្ងៃ យួន គេទុកខ្មែរ អ្នកការពារជាតិទាំងឡាយ ជាពួកអ្នកប្រកាន់ពូជសាសន៍, រីឯ ពួកខ្មែរបំរើយួន វិញ គេទុក អ្នកប្រឆាំងអំណាចយួន និង បនរបស់គេ ជាពួកអ្នកជ្រុលនិយម។

---

15 ទ្រឹស្តីនេះ មាននៅក្នុងទ្រឹសស្តីរបស់លោក ម៉ាក្ស ជាបិតា នៃលទ្ធិកុម្មុយនិស្ត។

# សិក្ខាបទ នៃព្រះដ៏មានព្រះភាគ



ព្រះដ៏មានព្រះភាគ

ដកស្រង់ពីព្រះត្រៃបិដក : បណ្ឌិតបុរសពោធិសត្វ ពោលថា : *ការប្រព្រឹត្តិ នូវសេចក្តីចំរើន របស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្តីសុខទេ, បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៏អោយសាបសូន្យ ដូចស្វារក្សារក្សាសួន បានធ្វើប្រយោជន៏អោយវិនាស។*

ន័យនេះ វាធៀបនឹង ក្រុមអ្នកប្រឆាំងណាមួយ តាំងខ្លួនជាអ្នករក្សាប្រយោជន៏ជាតិខ្មែរ តែឥតប្រាជ្ញា តែងធ្វើប្រយោជន៏អោយសាបសូន្យ ដូចស្វានោះដែរ។ ដូច្នេះ សេចក្តីស្នេហាជាតិ មិនគ្រប់គ្រាន់នោះទេ គឺអ្នកស្នេហាជាតិ ត្រូវមានប្រាជ្ញា ទើបអាចរក្សាប្រយោជន៏ជាតិបាន។

ដកស្រង់ពីព្រះត្រៃបិដក : ព្រះរាជាសីលវះពោធិសត្វ ពោលថា : *បុរសជាបណ្ឌិត គប្បីប៉ុនប៉ងអោយមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ។*

ន័យនេះ វាធៀបនឹង ការតស៊ូ ដើម្បីការពារប្រយោជន៏ជាតិខ្មែរ ត្រូវតែមានការប៉ុនប៉ងអោយច្បាស់លាស់ ទើបអាចសម្រេច នូវសេចក្តីប្រាថ្នានោះបាន។